# ការសម្ភាសរបស់លោកពូ អឿន អុន

**កៈ អ្នកសម្ភាស ញ៉ែម សុគន្ធា ខៈ អ្នកត្រូវគេសម្ភាស អឿន អុន**

កៈ ជាដំបូងនៅក្នុងថ្ងៃនេះនាងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូដែលបានឱ្យនាងខ្ញុំធ្វើការសម្ភាសអំពីជីវប្រវត្តិរបស់ពូ ហើយនាងខ្ញុំឈ្មោះ ញ៉ែម សុគន្ធា ជាអ្នកសម្ភាសនៅក្នុងថ្ងៃនេះ ហើយតើឈ្មោះពេញរបស់ពូមានឈ្មោះអីដែរ?

ខៈ ឈ្មោះ អុន អឿន។

កៈ ចាសហើយថ្ងៃហ្នឹងនាងខ្ញុំបានធ្វើការសម្ភាសលោកពូនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦។ ការសម្ភាសនេះត្រូវបានធ្វើឡើងដោយការរៀបចំពីសកលវិទ្យាល័យនៅសហរដ្ឋអាមេរិកដែលមានឈ្មោះថា ប៊ី វ៉ាយ យូ ដោយសកលវិទ្យាល័យនេះមានកម្មវិធីសម្ភាសអំពីប្រវត្តិរបស់លោកពូផ្ទាល់ក៏ដូចជាប្រជាជនខ្មែរយើងដើម្បីនាពេលអនាគតទៅឱ្យកូននិងចៅរបស់ពូក៏ដូចជាកូនចៅជំនាន់ក្រោយអាចស្វែងយល់អំពីជីវប្រត្តិនិងដំណើររឿងឆាកជីវិតនិងក៏ដូចជាឆាកជីវិតអញ្ចឹងណាពូ ចាសអញ្ចឹងតើលោកពូអាចអនុញ្ញាតិដើម្បីដាក់ការសម្ភាសនេះដាក់ចូលវេបសាយរបស់សាលាបានដែរឬទេពូបានទេពូ?

ខៈ បានៗ។

កៈ ដែលវេបសាយនេះមានឈ្មោះថា www.cambodiaoralhistory.byu.edu ហើយឥឡូវហ្នឹងនាងខ្ញុំនឹងធ្វើការចាប់ផ្តើមសម្ភាសអំពីជីវប្រវត្តិរបស់ពូដែរមានដូចតទៅនេះហើយ អញ្ចឹងសូមលោកពូជួយប្រាប់ឈ្មោះពេញមកខ្ញុំម្តងទៀតបានទេ?

ខៈ ឈ្មោះ អុន អឿន ។

កៈ អញ្ចឹលោកពូចាប់តាំងពីលោកពូនៅតូចរហូតដល់ធំ តើមានអ្នកណាដាក់ឈ្មោះហៅក្រៅឱ្យលោកពូអីដែរឬទេ?

ខៈ អត់មាន អត់មានផង។

កៈ អត់មានទេមានតែគេហៅថាពូអឿនៗហ្នឹងណោះ?

ខៈ បាទ!

កៈ ចាសអញ្ចឹងសម្រាប់លោកពូ តើពូកើតនៅជំនាន់ណាដែរលោកពូ?

ខៈ កើតនៅថ្ងៃអង្គារ ខែប្រាំបី។

កៈ ឆ្នាំណាដែរពូ?

ខៈ ឆ្នាំ១៩៨០។

កៈ ចាសអញ្ចឹង តើទីកន្លែងកំណើតនៅភូមិឃុំណាវិញដែរពូ?

ខៈ នៅភូមិជើងព្រៃ ឃុំអំពៅព្រៃ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

កៈ  ចាសអញ្ចឹងអរគុណច្រើនមែនទែន ចាសអញ្ចឹងឥឡូវហ្នឹងសម្រាប់ពូ តើពូអាយុប៉ុន្មានហើយណាពូ?

ខៈ  ឥឡូវ៣៦។

កៈ ចុះឆ្នាំខ្មែរវិញអញ្ចឹងសម្រាប់ឆ្នាំខ្មែរវិញណាពូអីឆ្នាំណាដែរពូ ជូត ឆ្លូវ ខាល ថោះណាពូ?

ខៈ ឆ្នាំវក។

កៈ ចាសអញ្ចឹងតើពូមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខៈ បងប្អូនប្រុស៣នាក់ ស្រី១។

កៈ ចាសអញ្ចឹងស្រីមួយ អញ្ចឹងតើពូជាកូនទីប៉ុន្មានដែរពូ?

ខៈ បងគេ។

កៈ ចាសអញ្ចឹងពូបងគេ?ចាសអញ្ចឹងពូតើបងប្អូនរបស់ពូ តើពួកគាត់រស់នៅទាំងអស់ឬមួយក៏ទៅនៅឯណាដែរឥឡូវហ្នឹងពូ?

ខៈ នៅទាំងអស់ហ្នឹងណា។

កៈ ហើយអញ្ចឹងតើគាត់រស់នៅជាមួយពូដែរឬទេ?

ខៈ នៅជាមួយម៉ែ។

កៈ នៅជាមួយម៉ែចាស អញ្ចឹងដូចជាប្រវត្តិរបស់ឪពុកលោកពូវិញម្ដង តើឪពុករបស់លោកពូតើគាត់មានឈ្មោះអ្វីដែរលោកពូ?

ខៈ ឪពុកគាត់ឈ្មោះ សារ៉ុន ប៉ុន្តែគាត់បានលែងគ្នាយូរហើយហ្នឹងណា។

កៈ ចាសអញ្ចឹងតើពូមានចាំពីថ្ងៃខែឆ្នាំកំណើតរបស់ឪពុករបស់លោកពូទេ?

ខៈ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៦៥ ។

កៈ ខែមិនាទេអី ចុះទីកន្លែងកំណើតរបស់ឪពុកពូនៅណាដែរពូ?

ខៈ ហ្នឹងហើយខែមិនា គេដាក់ថានៅភូមិវិមាន ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាលបាទ។

កៈ ចាសអញ្ចឹងពូមានចាំទេថាតើគាត់ឆ្នាំខ្មែរជាសត្វអ្វីដែរពូ?

ខៈ មិនចាំទេ។

កៈ ចាសអញ្ចឹងមិនចាំទេ ចាសអញ្ចឹងតើពូមានអនុស្សាវរីយ៍អ្វីខ្លះដែលពូមានការចងចាំអ្វីខ្លះដែរជាមួយនឹងឪពុករបស់ពូហ្នឹង តើគាត់ធ្លាប់បានផ្ដល់សុភមង្គលអ្វីគេខ្លះដែរមកឱ្យពូនិងគាត់ធ្លាប់បានចិញ្ចឹមបីបាច់ថែរក្សាពូ តើគាត់ជាមនុស្សបែបណាដែរលោកយាយ?

ខៈ អូ... គាត់ដូចជាមិនអីដែរហ្នឹង គាត់ធម្មតាទេណា ណាមួយគាត់ហ្នឹងគឺជាឪពុកចុងទេណា។

កៈ ចាសអញ្ចឹងហើយចុះអញ្ចឹងឪពុកបង្កើតរបស់ពូវិញហ្នឹងណា?

ខៈ អូ...គាត់មិនដឹងជាស្លាប់ឬក៏រស់ទេតែគាត់នៅភ្នំពេញ។

កៈ អញ្ចឹងតើគាត់ចាកចោលពូនៅពេលណាដែរពូ?

ខៈ អូ...តាំងពីតូចណោះ។

កៈ ហើយចុះអញ្ចឹងតើពូមានចងចាំអ្វីខ្លះដែរជាមួយគាត់?

ខ៖ មិនចាំទេ។

ក៖ ចាសអញ្ចឹងចាំឈ្មោះគាត់ឈ្មោះអីដែរ?

ខ៖ ឈ្មោះគាត់ត្រកូលខ្ញុំហ្នឹងណា ឈ្មោះអុនហ្នឹងប៉ុន្តែខ្ញុំក៏មិនដឹងដែរថាគាត់ទៅនៅឯណាទេ ត្រកូលគាត់មិនដឹងដែរ តែគាត់ឈ្មោះអុន។

ក៖ ចាសចុះសម្រាប់ម្ដាយរបស់ពូវិញ តើគាត់ៗឈ្មោះអ្វីដែរ?

ខ៖ ឈ្មោះ មាស ចាន់ថន។

ក៖ ចាសអញ្ចឹងតើគាត់កើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ ?

ខ៖ ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៦០។

ក៖ ចាសអញ្ចឹងទីកន្លែងកំណើតរបស់គាត់វិញ?

ខ៖ នៅភូមិជើងព្រៃ ឃុំអំពៅព្រៃ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។

ក៖ ចាសហើយអញ្ចឹងតើពូមានចាំទេថាតើគាត់ឆ្នាំខ្មែរខែណាដែរពូ?

ខ៖ អត់ចាំដែរហ្នឹង ម៉ែថាគាត់កើតឆ្នាំខ្មែរឆ្នាំណាទេ ព្រោះអីមិនដែរបានសួរគាត់ផងហ្នឹងណា។

ក៖ អញ្ចឹងអត់ដែរសួរទេ ចាសហ្នឹងហើយអញ្ចឹងតើសម្រាប់ពូ តើពូមានការចងចាំអ្វីខ្លះដែរ ជាមួយនឹងម្ដាយអ្វីខ្លះដែរ ដែលពូបានរស់នៅជាមួយម្ដាយរបស់ពូពីមុនហ្នឹងណា?

ខ៖ ចាសគាត់មិនដែលបានធ្វើឱ្យខ្ញុំពិបាកចិត្តទេណា តែគាត់តែជួយរកស៊ីយើងហ្នឹង គាត់បានខំប្រឹងចិញ្ចឹមបីបាច់ថែរក្សាយើងតាំងពីតូចៗទំរាំតែយើងបានប៉ុណ្ណឹងមកហ្នឹងណាមកទេហ្នឹងណាហើយមានអីគេគ្រាន់តែយើងជួយរកគាត់និងជួយសងគុណគាត់វិញទៅហ្នឹងណា ។

ក៖ ចាសហ្នឹងហើយអរគុណច្រើន ចាសអញ្ចឹងតើពូមានចាំបានខ្លះៗទេថា តើជីដូនជីតាខាងឪពុកពូតើគាត់មានឈ្មោះជីដូនជីតាខាងឪពុកទេ?

ខ៖ មិនដែលស្គាល់ទេខាងឪពុកហ្នឹង។

ក៖ ចាសអញ្ចឹងតើមានស្គាល់មុខគាត់អត់អញ្ចឹង?

ខ៖ ឃើញតើតែគ្រាន់តែយើងមិនស្គាល់ឈ្មោះ មិនស្គាល់ត្រកូលគាត់ទេហ្នឹងណា។

ក៖ ចាសអញ្ចឹងសម្រាប់ខាងម្ដាយវិញតើពូមានតាមានយាយអីអត់?

ខ៖ តាមានតែគាត់ស្លាប់អស់ទៅហើយហ្នឹងណា។

ក៖ ហើយអញ្ចឹងតើគាត់មានឈ្មោះអីដែរ?

ខ៖ ចេប ។

ក៖ ចាសហើយអញ្ចឹងមានដឹងពីថ្ងៃខែឆ្នាំកំណើតគាត់ដែរទេ?

ខ៖ មិនដឹងទេ។

ក៖ អញ្ចឹងតើឆ្នាំខ្មែរគាត់វិញ?

ខ៖ មិនដឹងដែរហ្នឹងណា ដឹងតែឈ្មោះគាត់ទេ បើប្រវត្តិគាត់ថាកើតនៅខែណាឆ្នាំណាមិនចាំទេ មិនដឹងទេ។

ក៖ ចាសអញ្ចឹងតើមានធ្លាប់បានលេងអីខ្លះជាមួយគាត់ទេកាលនៅពីក្មេងជាមួយគាត់ទេ?

ខ៖ និយាយរួមទៅកាលដែលគាត់នៅរស់ហ្នឹងខ្ញុំប៉ុនៗអាវិនហ្នឹងណា មិនដែលបានលេងជាមួយគាត់ទេ គាត់ដើរបាត់ៗចោលហ្នឹង មិនដែលបានឃើញមកលេងជាមួយនឹងយើងទេណា។

ក៖ ចាសអត់សោះ ចាសអញ្ចឹងតើយាយវិញគាត់មានឈ្មោះអីដែរ?

ខ៖ យាយគាត់ឈ្មោះយាយនួន ។

ក៖ ចាសអញ្ចឹងមានការចងចាំអីជាមួយគាត់ទេ?

ខ៖ មានតើកាលពេលដែលយើងនៅតូចៗហ្នឹងណា ពេលដែលយើងឈឺគាត់មកដេកជាមួយនឹងយើងហ្នឹង ហើយធ្លាប់បាននៅជាមួយគាត់ហ្នឹងណា គាត់ជួយមើលថែយើងអីហ្នឹងណា ជួយដាំបាយដាំទឹកឱ្យយើងហូប។

កៈ ចាសអញ្ចឹងតើមានចាំទេថាតើគាត់កើតនៅខែណាឆ្នាំណាដែរទេយាយតាខាងម្ដាយហ្នឹងណាពូ?

ខៈ និយាយរួមមិនចាំទេ មិនដែលដឹងអាហ្នឹងប្រវត្តិគាត់ហ្នឹងនោះ ។

កៈ ចាសអញ្ចឹងអត់អីទេ ចាសអញ្ចឹងតើតាយាយឪពុកម្ដាយបងប្អូនរបស់ពូតើមានអ្នកណាធ្លាប់បានទៅរស់នៅប្រទេសក្រៅទេគេដែរឬទេពូ?

ខៈ មិនធ្លាប់ទេគាត់នៅតែស្រុកខ្មែរហ្នឹងណា។

កៈ អញ្ចឹងគាត់ធ្លាប់រស់នៅតែស្រុកខ្មែរទេណោះ ចាសអញ្ចឹងចូលទៅដល់ការសិក្សារបស់ពូវិញថាតើពូអឿនរៀនបានថ្នាក់ទីប៉ុន្មានដែរពូ?

ខៈ រៀនបានថ្នាក់ទី៥។

កៈ អញ្ចឹងរៀននៅណាវិញដែរពូ?

ខៈ នេះនៅសាលាព្រែកកំពិសយើងនេះ។

កៈ ចាសហ្នឹងហើយបឋមសិក្សាព្រែកកំពឹសអញ្ចឹងហ្នឹងហើយ ហ្នឹងហើយអញ្ចឹងតើមានធ្លាប់បានរៀនភាសាផ្សេងក្រៅពីភាសាខ្មែរទេ?

ខៈ អត់ទេរកពេលរៀនមិនបានផងហ្នឹង រៀនបានតែថៃហ្នឹងបានតែបន្តិចៗហ្នឹងណាតែឥឡូវហ្នឹងភ្លេចអស់ទៅហើយហ្នឹងណា។

កៈ ហើយចុះអញ្ចឹងតើឥឡូវហ្នឹងមាននៅចាំបានភាសាថៃអត់ចេះសរសេរទេអញ្ចឹងណោះអញ្ចឹងហ្នឹងបានខ្លះទេអញ្ចឹង?

ខៈ អូ...អត់ទេ មិនចាំទេភ្លេចអស់ទៅហើយហ្នឹងណា កាលហ្នឹងរៀនបានតែមួយថ្ងៃហ្នឹងណា។

កៈ ចាសហើយអញ្ចឹងសម្រាប់ពូវិញថាតើពេលដែលពូរៀននៅពេលពីក្មេងហ្នឹង តើក្ដីស្រម៉ៃរបស់ពូហ្នឹងតើពូចង់ក្លាយទៅជាអ្វីដែរពូនៅពេលថ្ងៃអនាគតរបស់ពូ?

ខ៖ នៅពេលដែលយើងរៀនចេះតែចង់ធ្វើអីហើយធ្វើនេះធ្វើនោះអញ្ចឹងទៅហ្នឹងណា ចិត្តចង់ធ្វើជាប៉ូលីសតែដល់ពេលដែលយើងរៀនមិនចាំអញ្ចឹងទៅមិនដឹងជាធ្វើអីគេទេណា មានអីទេមានតែធ្វើការធម្មតាៗហ្នឹងទៅហ្នឹងណា។

ក៖ ចាសអញ្ចឹងសម្រាប់ក្ដីស្រម៉ៃចង់ធ្វើជាប៉ូលីសណោះពូ?

ខ៖ ហ្នឹងហើយ!

ក៖ ចាសអញ្ចឹងពូសម្រាប់ក្រុមគ្រួសាររបស់ពូវិញតាំងពីដើមមកតើគាត់ធ្វើស្រែចម្ការអីអត់?

ខ៖ ម្ដាយកាលពេលដែលខ្ញុំមិនទាន់ដឹងក្ដីមកប្រហែលជាគាត់ធ្លាប់ធ្វើហើយតែពេលដែលខ្ញុំដឹងក្ដីមកគាត់មិនដែរធ្វើទេឥឡូវនេះ ។

ក៖ ចាសអញ្ចឹងតើគាត់មានមុខរបរចិញ្ចឹមជីវិតអីគេដែរអញ្ចឹង?

ខ៖ គាត់ប្រកបមុខរបរបន្តិចបន្តួចនៅផ្ទះហ្នឹងណា រកស៊ីចិញ្ចឹមកូនចៅគាត់រកទាំងប្ដីទាំងប្រពន្ធគាត់អញ្ចឹងទៅហ្នឹងណា។

ក៖ អញ្ចឹងគាត់ជាអ្នករកស៊ីលក់ចាប់ហួយអញ្ចឹងទៅណោះអញ្ចឹង?អញ្ចឹងសម្រាប់ពូវិញអំពីការរៀបការវិញម្ដងតើពូចាំទេថាតើពូរៀបការនៅក្នុងឆ្នាំណាដែរពូ?

ខ៖ មិនដឹងទេនៀក មិនដឹងថាឆ្នាំ២០០១ឬក៏ឆ្នាំ២០០២ទេ។

ក៖ ហើយចុះមានចាំបានទេថានៅក្នុងខែណាដែរអត់?

ខ៖ អត់ចាំទេ។

ក៖ ចាសអញ្ចឹងសម្រាប់ការរៀបការ តើមានចាំទេថារៀបចំឡើងដោយឪពុកម្ដាយឬក៏ស្រលាញ់គ្នាដោយចិត្តឯង?

ខ៖ ស្រលាញ់គ្នាកាលហ្នឹង។

ក៖ ស្រលាញ់គ្នាដោយចិត្តឯង រួចអញ្ចឹងក៏ម្ដាយឪពុកផ្សំផ្គុំឱ្យអញ្ចឹងទៅណោះ?

ខ៖ ហ្នឹងហើយ!

ក៖ ចាសអញ្ចឹងតើពេលដែលបានជួបគ្នាជាមួយនឹងប្រពន្ធពូលើកដំបូងហ្នឹងនៅណាវិញដែរពូ?

ខ៖ នៅរោងចក្រយើងខាងកែងហ្នឹងណា ពេលធ្វើការ។

ក៖ ចាសហ្នឹងហើយ អញ្ចឹងតើគេហៅរោងចក្រអីគេវិញដែរពូ?

ខ៖ រោងចក្រស្អីទេគេហៅថារោងចក្រកម្ពុជា រោចក្រកាត់ដេរហ្នឹងណា នៅជិតវត្តគោករលួសហ្នឹងណា។

ក៖ ចាសហ្នឹងហើយ អញ្ចឹងពេលដែលឃើញប្រពន្ធដំបូងហ្នឹងម្ដេចបានជាចាប់ចិត្តស្រលាញ់?

ខ៖ ខ្ញុំមិនដឹងដែរពេលហ្នឹង មិនដឹងម្ដេចដែរកាលហ្នឹង ភ្លេចអស់ទៅហើយហ្នឹង។

ក៖ ចាសអញ្ចឹងពេលហ្នឹងអញ្ចឹងភ្លេចអស់ទៅហើយណោះប្រវត្តិហ្នឹងអញ្ចឹង?អញ្ចឹងពេលហ្នឹងឃើញគ្នាអញ្ចឹងទៅក៏ចាប់ចិត្តស្រលាញ់គ្នាអញ្ចឹងទៅអញ្ចឹង។

ខ៖ ហ្នឹងហើយ!

ក៖ ចាសអញ្ចឹងតើពេលហ្នឹងពូមានបានឱ្យបណ្ដាការការអីខ្លះទៅដល់ខាងប្រពន្ធទេពូ?

ខ៖ មានតើ។

ក៖ ចាសហើយអញ្ចឹងតើឱ្យជាមាសឬក៏ជាប្រាក់ឬក៏ជាអ្វីដែរទៅខាងប្រពន្ធហ្នឹង?

ខ៖ កាលហ្នឹងជាលុយទេ។

ក៖ ចាសអញ្ចឹងអញ្ចឹងជាលុយទេណោះ ចាសអញ្ចឹងប្រៀបបធៀបសម្រាប់ជីវិតរបស់ពូវិញណាពូតើជីវិតរបស់ពូពីអតីតកាលនិងសម្រាប់បច្ចុប្បន្នកាលតើមានភាពខុសគ្នាដូចម្ដេចខ្លះដែរពូ ដូចជាពីតូចមកយ៉ាងម្ដេចហើយធំឡើងយ៉ាងម្ដេចដែរ?

ខ៖ ពីតូចរៀងយ៉ាប់ប៉ុន្តែពេលដែលធំមកយើងមានប្រពន្ធមានកូនអីទៅហ្នឹងណាក៏បានរៀងស្រួលបន្តិចទៅហ្នឹងណា ព្រោះយើងខំប្រឹងរកអញ្ចឹងកូនបានអីស៊ី ណាមួយឥឡូវហ្នឹងកូនវាចូលរៀនផងហ្នឹងណាឥឡូវនេះ។

ក៖ ចាសអញ្ចឹងដូចជាជីវិតហ្នឹងខុសគ្នាណោះ?

ខ៖ បាទហ្នឹងហើយវាមានភាពខុសគ្នាបន្តិចៗហ្នឹងទៅ។

ក៖ ចាសអញ្ចឹងសម្រាប់ចំណង់ចំណូលចិត្តរបស់ពូវិញ តើពូចូលចិត្តម្ហូបអីដែរដែលពូចូលចិត្តធ្វើជាងគេដែរ សម្រាប់សម្លរអីហ្នឹងណា?

ខ៖ ម្ជូរអីហ្នឹង ហើយនឹងអីក្រៀមៗត្រីប្រឡាក់ឪឡឹកអីហ្នឹងណា។

ក៖ ចាសហ្នឹងហើយ អញ្ចឹងតើពូចេះធ្វើម្ហូបអីដែរពូ ចូលចិត្តហូបហ្នឹងដែរទេពូ?

ខ៖ អត់ទេ។

ក៖ អត់ទេ អញ្ចឹងការធ្វើម្ហូបហ្នឹងអ្នកណាគេជាអ្នករៀបចំឱ្យដែរអញ្ចឹង?

ខ៖ តែម៉ែហ្នឹងណា ជូនម៉ែជូនប្រពន្ធតែភាគច្រើនតែម៉ែក្មេកគាត់នៅផ្ទះគាត់ជាអ្នករកឱ្យហើយហ្នឹងណា។

ក៖ ចាសអញ្ចឹងសម្រាប់ពេលដែលទំនេរវិញ តើពូចូលចិត្តធ្វើអីគេវិញដែរពេលដែលទំនេរ?

ខ៖ ពេលដែរទំនេរនៅផ្ទះចូលចិត្តធ្វើការងារផ្ទះ។

ក៖ ចាសអញ្ចឹងតើកិច្ចការផ្ទះហ្នឹងចូលចិត្តធ្វើអីគេដែរពូ?

ខ៖ ទៅមើលការងារនៅដី កាយទឹកកាយអីហ្នឹងទៅហ្នឹងណា បោសផ្ទះបោសអីអញ្ចឹងទៅជួយធ្វើការងារម៉ែក្មេកតិចតួចៗអញ្ចឹងទៅហ្នឹងណា។

ក៖ ចាសអញ្ចឹងសម្រាប់ពេលដែលពូទំនេរពីរការងារផ្ទះអញ្ចឹង តើពេលដែលពូទំនេរពីការងារទាំងអស់ហ្នឹងតើពូចូលចិត្តទៅកម្សាន្តនៅកន្លែងណាជាងគេដែរពូ?

ខ៖ ចូលចិត្តជាងគេណោះ?

ក៖ ចាសហ្នឹងហើយ។

ខ៖ ដូចជាកំពត កំពង់សោមទេតែពីរហ្នឹងទេដែលចូលចិត្តទៅ។

ក៖ ចាសអញ្ចឹងចូលចិត្តហ្នឹងជាងគេណោះ ហើយអញ្ចឹងតើមានធ្លាប់បាននាំកូននាំប្រពន្ធទៅទាំងអស់គ្នានៅអញ្ចឹង?

ខ៖ អេស...ដូចជានៅទេ អាទីអីដូចជាធ្លាប់បានទៅហើយ នៅតែអាវិតទេបានទៅតែអាទីមួយទេ។

ក៖ អញ្ចឹងបានតែអាបងទេ អាប្អូនហ្នឹងវានៅតូចពេក។

ខ៖ ហ្នឹងហើយអាទីបានទៅកំពត បានទៅកំពង់សោម។

ក៖ ចាសហ្នឹងហើយ ចាសអញ្ចឹងពូដូចជាពូចូលចិត្តស្តាប់ចម្រៀងទេ?

ខ៖ មិនសូវជាចូលចិត្តទេ។

ក៖ អញ្ចឹងមិនសូវស្តាប់ចម្រៀងច្រើនទេណោះ?

ខ៖ ហ្នឹងហើយ!

ក៖ ចាសហ្នឹងហើយ អញ្ចឹងពូមានអ្នកចម្រៀងដែលសំណព្វចិត្តជាងគេដូចជាចូលចិត្តពីណាគេជាងគេសម្រាប់អ្នកចម្រៀង?

ខ៖ ចូលចិត្តជាងគេមានតែព្រាប សុវត្ថិទេ តែចម្រៀងវាខ្ញុំស្តាប់បានតែម្តងៗទេអាហ្នឹង។

ក៖ ចាសអញ្ចឹងតើពូចេះលេងឧបករណ៍តន្ត្រីអីដែរឬទេពូ?

ខ៖ អត់ទេ ។

ក៖ ចាសអញ្ចឹងតើមានបងប្អូនណាគាត់ចេះលេងឧបករណ៍តន្ត្រីទាំងអស់ហ្នឹងដែរឬទេ?

ខ៖ អត់មានទេ។

ក៖ ចាសអញ្ចឹងដូចជាពូកើតនៅក្នុងឆ្នាំប៉ែតជាងបែតប៉ុន្មានពូ?

ខ៖ ប៉ែតគត់ ។

ក៖ ប៉ែតគត់ ចាសអញ្ចឹងពេលខ្លះតែងតែពេលខ្លះមានការជំណាលរឿងអំពីខ្មែរយើងកាលពីជំនាន់មុនៗហ្នឹងណាក៏ដូចជាជំនាន់លន់ នល់និងជំនាន់ប៉ុល ពតអីវ៉ាន់ហើយតើរបបហ្នឹងវាមានការលំបាកម្តេចខ្លះដែរក៏ដូចជា?

ខ៖ អូ...អាហ្នឹងដូចជាមិនជាសូវដឹងទេនៀក យើងមិនសូវជាបានចាប់អារម្មណ៍និងមិនសូវជាបានស្តាប់ដែរហ្នឹងណា។

ក៖ អញ្ចឹងពូតើពូអាចប្រាប់ខ្ញុំបានទេថាពីកាលពីមុនមកប្រទេសយើងតែងតែជួបសង្គ្រាមហើយមែនទេបង អញ្ចឹងពេលដែលបងនៅរៀនក៏ដូចជាឮចាស់ៗនិយាយតៗគ្នាមក តើសង្គ្រាមនៅក្នុងប្រទេសខ្មែរយើងវាជួបនឹងបញ្ហាអ្វីខ្លះដែលគេតែងតែនិយាយតៗគ្នាឬមួយក៏ឪពុកម្តាយបងឬក៏ជីដូនជីតាពូណា ដូចជាសម័យប៉ុល ពតសម័យលន់ នល់អីអញ្ចឹងហ្នឹងណា?

ខ៖ គាត់មិនដែលរៀបរាប់ប្រាប់ផង ប្រហែលជាពិបាកពេកហើយបានជាគាត់មិនដែលប្រាប់ខ្ញុំអញ្ចឹងបានជាមិនដែលបានឮម្តាយខ្ញុំរៀបរាប់ប្រាប់ផង។

ក៖ ចាសហើយម្តាយរបស់ពូមិនដែលបានប្រាប់រឿងរ៉ាវនិងប្រវត្តិរបស់ពួកគាត់ហ្នឹងណាដែលពេលហ្នឹងតើពួកគាត់បានជួបនូវរឿងរ៉ាវដូចម្តេចខ្លះដែរអីទៅដល់ពូទេណោះអញ្ចឹង?

ខ៖ ពួកគាត់មិនដែលប្រាប់អីយើងផងហ្នឹងណា គាត់មិនដែលប្រាប់យើងផងហ្នឹងណា។

ក៖ អញ្ចឹងគាត់មិនដែលប្រាប់យើងទេណោះថាវាពិបាកម្តេចទេណោះ?

ខ៖ ហ្នឹងហើយអត់ទេ គាត់មិនដែលប្រាប់ទេថាយើងពិបាកម្តេច ចាប់តាំងពីតូចរហូតមកដល់ពេលនេះគាត់មិនដែលប្រាប់យើងទេថាពិបាកម្តេចនោះទេ។

ក៖ ចាសហ្នឹងហើយ អញ្ចឹងបងស្រីតើបងប្អូនរបស់ម្តាយឪពុករបស់បងក៏ដូចជាសាច់ញាតិរបស់បងតើបានរួចផុតពីរបបប៉ុល ពតហ្នឹងហើយរស់នៅដល់សព្វថ្ងៃដែរបងស្រី?

ខ៖ ម៉ាក់ខ្ញុំគាត់ថាកាលពីពេលហ្នឹងបិសគេយកគាត់ទៅវាយចោលណា តែសំណាងដោយសារតែគាត់ចេះដើរកោសខ្យល់ឱ្យគេ ប៉ះខោអាវខោអីឱ្យគេអញ្ចឹងទៅក៏បានរួចខ្លួនទៅ។

ក៖ ចាសហ្នឹងហើយអញ្ចឹងបានគេឱ្យអីហូបដែរ?

ខ៖ ចាសដោយសារតែគាត់ចេះកោសខ្យល់កោសអីឱ្យគេអញ្ចឹងទៅ ហើយគេឃើញគាត់ល្អក៏គេមិនសម្លាប់គាត់ហ្នឹងណា ហើយបើគាត់ទៅលួចអីគេហ្នឹងគេនឹងវាយចោលហើយ ព្រោះតាខ្ញុំហ្នឹងគេយកទៅវាយចោលហើយ កុងខាងម៉ាក់ហ្នឹង។

កៈ អញ្ចឹងតារបស់បងហ្នឹងគាត់ស្លាប់កាលពីជំនាន់ប៉ុល ពត ចាសអញ្ចឹងបងដូចជាអ៊ុំអីហ្នឹងដែលគាត់នៅសល់មានរស់រានជីវិតមកហ្នឹងណា តើគាត់ប្រកបរបរអីដែរពេលចេញមកពីជំនាន់ប៉ុល  ពតវិញ?

ខៈ យាយខ្ញុំគាត់ដូចជាអត់មានប្រកបរបរអីផងហ្នឹងពេលដែលបែកមកដូចថាគាត់សល់ពីតាខ្ញុំមក

បន្តិចបន្តួចទៅ ហើយគាត់រកស៊ីចងការប្រាក់ឱ្យគេអីបន្តិចបន្តួចហ្នឹង ប៉ុន្តែឥឡូវហ្នឹងគេបោកអស់បោកអស់អាលីងតែហ្មងហ្នឹង ហើយរាល់ថ្ងៃដីនៅឯស្រុកហ្នឹងដូចថាគាត់ចិត្តល្អដូចថាអ្នកអត់មានផ្ទះអត់មានអីនៅអញ្ចឹងទៅគាត់ឱ្យគេធ្វើផ្ទះធ្វើអីនៅ អញ្ចឹងទៅដល់តែយូរៗទៅមានណាហើយគាត់ឱ្យគេធ្វើខ្ទមធ្វើអីនៅអញ្ចឹងទៅហ្នឹងណា តែដល់គាត់ស្លាប់បាត់ទៅនៅតែមួយច្រកផ្ទះដល់ហើយទៅឥឡូវពូខ្ញុំគាត់លក់បាត់ហើយ រួចគាត់ទៅនៅឯព្រែកអំបិលណោះ។

កៈ ចាសអញ្ចឹងសម្រាប់របស់ពូវិញ តើពូចងចាំអ្វីជាងគេដែរនៅក្នុងជីវិរបស់ពូហ្នឹងណាសម្រាប់ទាំងពេលដែលសប្បាយនិងពេលវេលាដែលកើតទុក្ខហ្នឹងណាពូ អ្វីដែលធ្វើឱ្យពូចងចាំជាងគេនៅក្នុងជីវិតរបស់ពូដែរហ្នឹងណាពូ?

ខៈ ចងចាំជាងគេណោះ?

កៈ ចាសហ្នឹងហើយដូចជាការសប្បាយរីករាយអីរ៉ាន់ឬក៏រំភើបអីឬក៏កើតទុក្ខអីហ្នឹងណា ពូដែលបានកើតមាននៅក្នុងជីវិតជាងគេអញ្ចឹងហ្នឹងណា វាជារឿងអីគេដែរ?

ខៈ មានរឿងអីសំខាន់ខ្លាំងទេ មានតែការសប្បាយពេលដែលបាននៅជួបជុំបងប្អូនអញ្ចឹងហ្នឹងណា ពេលដែលយើងមានបងប្អូនអញ្ចឹងទៅហ្នឹងណា យើងចង់ជួបជុំបងប្អូនអញ្ចឹងទៅហ្នឹងណាតែបើសិនជាយើងមិនមានលុយវិញក៏មិនដឹងថាជាសប្បាយចេញដែរហ្នឹងណា។

កៈ ចាសហ្នឹងហើយ អញ្ចឹងដូចជាការដែរចងចាំរួចដក់នៅក្នុងចិត្តជាងគេហ្នឹងណា ដូចជាពេលដែលមានកូន ពេលដែលអីអញ្ចឹងអីហ្នឹងណា តើពេលវេលាមួយណាដែរៗធ្វើឱ្យពូចងចាំជាងគេនៅក្នុងជីវិត?

ខៈ សំខាន់មានអីទេបើសិនជាកូនៗរៀបការអស់ទៅយើងហ្នឹងចងចាំហើយហ្នឹងណា។

កៈ ចាសហ្នឹងហើយ អញ្ចឹងបន្ទាប់ពីក្រោយរៀបអាពាហ៍ពិពាហ៍ជាមួយនឹងមីងមកតើពូមានកូនប៉ុន្មាននាក់ដែរបន្ទាប់ពីការរៀបការមក?

ខៈ មាន៣។

កៈ មាន៣ ចាសអញ្ចឹងមានស្រីប៉ុន្មានប្រុសប៉ុន្មាននាក់ដែរ?

ខៈ ប្រុសទាំង៣។

កៈ ហើយតើអញ្ចឹង តើពូអាចប្រាប់ពីឈ្មោះរបស់ពួកគាត់ទាំងអស់គ្នាបានទេដែរឬទេឈ្មោះពេញណា?

ខៈ កូនបងឈ្មោះអីទេ ដូចជាអុន ប្រុសនីតអី អុន ប្រុសនីត ហើយកូនទី២ អុន ប្រុសវិត ហើយកូនទី៣ អុន សិលា ។

កៈ ចាសអាឡាៗហ្នឹង?ហ្នឹងហើយចាសហ្នឹងហើយ អញ្ចឹងសម្រាប់ប្រពន្ធរបស់ពូវិញតើគាត់មានឈ្មោះអីដែរពូ?

ខៈ គាត់ឈ្មោះ ឃន ស្រីនាង ។

កៈ ឃន ស្រីនាង ចាសហើយអញ្ចឹងតើប្រពន្ធរបស់ពូហ្នឹងណា តើគាត់ជាមនុស្សម្តេចដែរពូ គាត់ជាមនុស្សមានចរិកលក្ខណៈម្តេចដែរពូអាចរៀបរាប់ខ្លះៗបានដែរឬទេពូ ដូចជាគាត់ហ្នឹងជាមនុស្សស្រីម្តេចដែរពូ?

ខៈ មានអីទេគាត់គឺជាមនុស្សស្រីធម្មតាៗ មានលក្ខណៈធម្មតាដូចគេដូចឯងអញ្ចឹងទៅហ្នឹងណា ។

កៈ ហើយអញ្ចឹងដូចជាគាត់ល្អម្តេចខ្លះដែរ?

ខៈ ហ្នឹងហើយគាត់ជាមនុស្សស្រីដែលល្អ ចេះដឹងចាស់ទុំម៉ែឪអីអញ្ចឹងទៅហ្នឹង បងប្អូនអញ្ចឹងទៅហ្នឹងណា ហើយមិនចេះឆេវឆាវអាឡេវអាឡូវដាក់បងដាក់ប្អូនទេហ្នឹងណា។

កៈ ចាសដូចជាពេលដែលគាត់រៀបចំទុកដាក់ រៀបចំម្ហូបឱ្យហ្នឹងណា តើអញ្ចឹងពូចូលចិត្តនូវអ្វីដែលជាស្នាដៃរបស់គាត់ទេ?

ខ៖ បាទហ្នឹងហើយពេលដែលយើងចង់ហូបអីអញ្ចឹងទៅយើងប្រាប់គាត់ទៅ គាត់ក៏ធ្វើឱ្យយើងហូបហើយហ្នឹងណា។

ក៖ ចាសហ្នឹងហើយ អញ្ចឹងហូបត្រូវមាត់អីអញ្ចឹងទៅហ្នឹងណោះ?

ខ៖ បាទហ្នឹងហើយហូបត្រូវមាត់ត្រូវអីហ្នឹងណា។

ក៖ ចាសអញ្ចឹងសម្រាប់ឥឡូវ សម្រាប់ជីវិតរបស់ពូអឿនវិញ តើពូអឿនប្រកបរបរអ្វីដែរសម្រាប់ចិញ្ចឹមជីវិតនៅពេលសព្វថ្ងៃហ្នឹងណាពូ?

ខ៖ បើកឡានរាល់ថ្ងៃហ្នឹង។

ក៖ រាល់ថ្ងៃហ្នឹងបើកឡានហ្នឹងហើយ អញ្ចឹងម្តេចដែរទទួលបានកម្រៃអំពីការបើកឡាននៅពេលសព្វថ្ងៃហ្នឹង?

ខ៖ អើយ...រាល់ថ្ងៃហ្នឹងអាអើយប្រាក់ខែស៊ីមិនគ្រប់ផងហ្នឹងណា។

ក៖ ចាសអញ្ចឹងសម្រាប់ប្រពន្ធវិញតើគាត់ធ្វើការអីគេដែរ?

ខ៖ គាត់ធ្វើការរោងចក្រ។

ក៖ រោងចក្រចាសអញ្ចឹងទាំង២នាក់ហ្នឹង តើជួយគ្នាយ៉ាងម្តេចដែរ?

ខ៖ និយាយរួមជួយរកគ្នាទៅ មួយខែគ្រាន់តែកូនរៀនមួយខែៗពីរ បីរយមិនចង់គ្រាន់ផងហ្នឹងណាគ្រាន់តែលុយកូនរៀននៅក្នុងមួយថ្ងៃៗចំណាយរួមទាំងម្ហូបទាំងអស់បួន ប្រាំម៉ឺនហើយហ្នឹងណាមួយខែៗបួន ប្រាំរយមិនគ្រាន់ទេណាមួយខែៗបួន ប្រាំរយមិនគ្រាន់ដែរហ្នឹងណា។

ក៖ ចាសហ្នឹងហើយ?

ខ៖ ហ្នឹងហើយធ្វើម្តេចបើវាពិបាកអញ្ចឹងទៅហើយចេះតែខំៗប្រឹងរកទៅហ្នឹងណា ទំរាំតែបានមួយឆ្នាំ ពីរឆ្នាំហ្នឹងណាបានសង់គេរួចអស់ទៅហ្នឹងណា វាគ្រាន់បន្តិចហើយហ្នឹងណាបានស្រួលជាងមុនហ្នឹងណាចេះតែទ្រាំៗទៅហ្នឹងណា ។

ក៖ ចាសហ្នឹងហើយ អញ្ចឹងតើអញ្ចឹងរាល់ថ្ងៃហ្នឹងតើពូនៅផ្ទះជាមួយនឹងអ្នកណាគេខ្លះដែរពូ?

ខ៖ មានប្រពន្ធកូន៣នាក់រួចហើយនឹងម្ដាយក្មេកទាំងអស់វាប្រាំមួយ ប្រាំពីរនាក់ហ្នឹងណា។

ក៖ ចាសហ្នឹងហើយ អញ្ចឹងតើការរស់នៅជាមួយម្ដាយវិញម្ដេចដែរតើមានសុភមង្គលទេ?

ខ៖ ធម្មតាទេអារឿងហ្នឹងនោះ អត់មានអីដែរហ្នឹងណា។

ក៖ អូ...ចាសអញ្ចឹងពូអឿនអារបៀបដែរពូចិញ្ចឹមបីបាច់ថែរក្សារកូនអញ្ចឹងហ្នឹងណា តើពូអប់រំមើលថែទាំពួកគាត់ហ្នឹងដូចម្ដេចដែរឱ្យពួកគាត់ហ្នឹងដើរលើផ្លូវម្ដេចខ្លះដែរ ពូធ្វើរបៀបម្ដេចដែរពូតើឱ្យពួកគាត់ដើរនៅលើសង្គមហ្នឹងដូចម្ដេចខ្លះដែរ?

ខ៖ និយាយរួមចេះតែអប់រំនិងប្រដៅវាទៅហ្នឹងណា កុំឱ្យវាចេះតែដើរលេងអាលៀតេ អាហ្នឹងវាមិនល្អទេដូចកូនគេអីអញ្ចឹងមិនល្អទេអាហ្នឹង បាទហ្នឹងហើយ ។

ក៖ ចាសអញ្ចឹងដូចជាអប់រំឱ្យពួកគាត់ជៀសផុតពីផ្លូវអីគេដែរពូ?

ខ៖ ឱ្យវាជៀសផុតពីគ្រឿងញៀនគ្រឿងអីហ្នឹងទៅណា កុំឱ្យវាដូចជាកូនគេកូនឯងអីអញ្ចឹងទៅហ្នឹងណា ព្រោះណាមួយយើងដឹងស្រាប់ហើយថាសង្គមយើងរាល់ថ្ងៃហ្នឹងវាម្ដេចដែរសំខាន់តែអាហ្នឹងមួយទេ បើអាហ្នឹងវាផុតៗហើយរួចហើយហ្នឹងឱ្យវាខំប្រឹងរៀនខំអី។

ក៖ ចាសហ្នឹងហើយ អញ្ចឹងតើពូដូចជាបានឱ្យកូនប្រុសទាំង៣នាក់ពូហ្នឹងទៅសិក្សាបានគ្រប់ៗគ្នាទេពូ?

ខ៖ បានទៅតើ បានរៀនគ្រប់ៗគ្នាទាំងអស់ហ្នឹងណា។

ក៖ ចាសអញ្ចឹងអាបងគេរៀនបានថ្នាក់ទីប៉ុន្មានៗអស់ហើយអញ្ចឹង?

ខ៖ អាទិកថ្នាក់ទីប៉ុន្មានទេ ដូចជាបានថ្នាក់ទី៧ ហើយចូលទី៧ហើយ។

ក៖ ចាសហ្នឹងហើយ អញ្ចឹងសម្រាប់ពូវិញតើមូលហេតុអីដែរបានជាពូឱ្យកូនពូទាំងបីហ្នឹងទៅសិក្សាវិញណាពូ?

ខ៖ ឱ្យវាទៅរៀនហ្នឹងដើម្បីឱ្យពួកវាហ្នឹងទៅរកអនាគតខ្លួនវាទុកសម្រាប់ទៅធ្វើការធ្វើអីអញ្ចឹងទៅហ្នឹងណា ឱ្យបានចេះដឹងដូចជាគេដូចជាឯងអញ្ចឹងទៅហ្នឹងណា បានធ្វើការងារ។

កៈ ចាសអញ្ចឹងតើដូចជាតម្លៃនៃការអប់រំមានតម្លៃយ៉ាងម្តេចដែរសម្រាប់ពូអឿន?អាហ្នឹងដូចជាម្តេចបានជាពូអឿនហ្នឹងណាចង់បានឱ្យកូនទាំងអស់ហ្នឹងបានទៅរៀនដូចជាកូនគេ?

ខៈ អូ...អាហ្នឹងយើងចង់ឱ្យវាល្អហ្នឹងណា ព្រោះណាមួយអីឡូវហ្នឹងប្រទេសយើងគេត្រូវការអ្នកចេះដឹងច្រើន អញ្ចឹងយើងចង់ឱ្យកូនទៅរៀនទៅ ទៅអីហ្នឹងទៅ បានរៀនទៅបានធ្វើការបានអីហ្នឹងទៅណា កុំឱ្យយើងចេះតែណែនាំវាឱ្យដើរទៅមុខទៅដើរតែផ្លូវល្អទៅហ្នឹងណា ។

កៈ ចាសហ្នឹងហើយ អញ្ចឹងខ្ញុំបានដឹងថាក្រុមគ្រួសារពូពិតជាល្អមែនទែនអញ្ចឹងតើពូជួយធ្វើបែបណាដើម្បីឱ្យក្រុមគ្រួសាររបស់ពូមានសុភមង្គល?តើពូដូចជាមានវិធានការបែបណាដែរៗពូអាចជួយឱ្យក្រុមគ្រួសាររបស់ពូមានសុភមង្គលហ្នឹងណា?

ខៈ អាហ្នឹងមានតែយើងហ្នឹងខំជួយគ្នាហ្នឹងណា ជួយគ្នាជួយរកគ្នាហ្នឹងទៅ អាហ្នឹងវាមានអីទេបើយើងមានកូនចៅទៅហើយមានតែដើរទៅមុខទេ មិនអាចដើរថយក្រោយវិញបានទេអាហ្នឹងនោះមានអីមានតែខិតខំប្រឹងប្រែងជួយរកគ្នាទៅហ្នឹងណា អញ្ចឹងបានមានសុភមង្គលទៅមុខ។

កៈ ចាសហ្នឹងហើយ អាហ្នឹងដល់តែយើងហ្នឹងខិតខំប្រឹងប្រែងជួយគ្នាបានទៅរួច ចាសហ្នឹងហើយ អញ្ចឹងតើពូមានគំនិតយោបល់អ្វីផ្សេងទៀតទេអាចបន្ថែមបាន?

ខៈ អត់ទេមានតែប៉ុណ្ណឹង។

កៈ ចាសអញ្ចឹងសម្រាប់ក្រុមគ្រួសារពេលដែលរៀបការហើយមានកូនមានចៅឬក៏មានអីមួយពេលខ្លះដូចជាគេថាចាននៅក្នុងរាវតែងតែទង្គិចគ្នាអញ្ចឹងហ្នឹងណាពូ អញ្ចឹងតើពេលដែលពូបញ្ហាតើពូមានដំណោះស្រាយយ៉ាងម្តេចដែរដើម្បីឱ្យមានសុភមង្គលបានឡើងវិញ ដូចជាពូដោះស្រាយបញ្ហាទាំងអស់ហ្នឹងម្តេចដែរពូ?

ខៈ ដោះស្រាយមានអីទេ បើសិនជាយើងដោះស្រាយវាមិនចេញមានតែយើងឱ្យបងប្អូនយើងហ្នឹងជួយដោះស្រាយបញ្ហាយើងហ្នឹងបន្តិចម្នាក់ៗហ្នឹងទៅណា បើយើងដោះមិនចេញទៅហើយមានតែបងប្អូនម៉ែក្មេកអីអញ្ចឹងទៅណាជួយដោះស្រាយទៅ។

កៈ ដូចជាពេលដែលពិបាកអញ្ចឹងតើពូដោះស្រាយម្តេចដែរ?ជួយនិយាយម្តេចខ្លះទៅអញ្ចឹងណា?

ខៈ មកជួយសម្រួលដោះស្រាយគ្នាហ្នឹងទៅហ្នឹងណា អាហ្នឹង។

កៈ ចាសហ្នឹងហើយ អញ្ចឹងដើម្បីឱ្យក្រុមគ្រួសាររបស់ពូមានភាពជិតស្និទ្ធនឹងគ្នា តើពូធ្វើអីគេដែរធ្វើអីខ្លះដើម្បីឱ្យក្រុមគ្រួសារមានភាពជិតស្និទ្ធ?

ខៈ អាហ្នឹងមានអីទេ មានតែយើងហ្នឹងធ្វើតែល្អៗទៅហ្នឹងណាជាមួយកូនជាមួយប្រពន្ធកុំអាណ្វងអាណាំងនៅក្នុងក្រុមគ្រួសារប្ដីប្រពន្ធកូនចៅអីអញ្ចឹងអីទៅហ្នឹងណា យើងខំអត់ធ្មត់រៀងៗខ្លួនទៅហ្នឹងណា អាហ្នឹងយើងបានសុភមង្គលហើយទៅថ្ងៃមុខហ្នឹងណា ។

កៈ ចាសអញ្ចឹងពិតជាល្អមែនទែនណោះពូ ចាសអញ្ចឹងសម្រាប់ជីវិតរបស់ពូវិញតើក្រុមគ្រួសារមានសារៈសំខាន់ម្ដេចខ្លះដែរសម្រាប់នៅក្នុងជីវិតរបស់ពូហ្នឹងណា?

ខៈ វាសំខាន់ៗហើយអាហ្នឹងនោះ កូននិងប្រពន្ធនោះទាំងប្រពន្ធទាំងកូនហ្នឹងណា។

កៈ អញ្ចឹងបើសិនជាពូរស់នៅម្នាក់ឯងតើពូសប្បាយទេអញ្ចឹង?

ខៈ អត់សប្បាយទេ។

កៈ ចុះដល់ពេលមានពួកគាត់?

ខៈ អាហ្នឹងវាសប្បាយ។

កៈ ចាសហ្នឹងហើយ អញ្ចឹងសម្រាប់ការសម្ភាសមួយហ្នឹងខ្ញុំនឹងឱ្យទៅកូនចៅរបស់ពូជំនាន់ក្រោយបានឮនៅរាប់រយតំណរបស់ដូនតារបស់ពួកគាត់ហ្នឹង អញ្ចឹងហ្នឹងបានឮទៅដល់ពួកគាត់ ចាសអញ្ចឹងតើពូមានពាក្យពេចន៍អ្វីខ្លះដើម្បីចែកចាយទៅកាន់ពួកគាត់និងការប្រៀនប្រដៅនិងផ្ដែផ្ដាំទៅកាន់ពួកគាត់ហ្នឹងណា ដែលជាពាក្យល្អៗដែលពូចង់ប្រាប់ទៅកូនចៅរបស់ពូជំនាន់ក្រោយ សម្រាប់កូនចៅរបស់ពូជំនាន់ក្រោយដែលបានស្ដាប់ឮ ចាសអញ្ចឹងតើពូមានអ្វីខ្លះដែរសម្រាប់ចែករំលែក?

ខៈ ខ្ញុំសូមណែនាំទៅកូនចៅជំនាន់ក្រោយកុំធ្វើធ្មេចភ្នែកផងមុននឹងធ្វើអ្វីមួយឱ្យមើលសង្គមផងកុំដើរអាលៀប៉ែដើរជក់តែថ្នាំ កុំធ្វើអញ្ចឹងអីវាមិនល្អទេហ្នឹងហើយ។

កៈ ចាសហ្នឹងហើយ អញ្ចឹងសម្រាប់ពូវិញតើពូមានបទពិសោធន៍អ្វីដែលល្អៗដែលចង់ចែកចាយទៅដល់កូនចៅជំនាន់ក្រោយនឹងឮពីពាក្យសម្ដីរបស់ពូអញ្ចឹងណា?

ខ៖ សូមណែនាំទៅកាន់កូនចៅជំនាន់ក្រោយហ្នឹងថាមានអីទេមានតែប្រាប់ទៅក្មេងជំនាន់ក្រោយហ្នឹងថាឱ្យវាធ្វើតែតាមដំណើរហ្នឹងទៅ ឱ្យវាធ្វើតែល្អហ្នឹងទៅហ្នឹងណា។

ក៖ ចាសអញ្ចឹងល្អមែនទែនពូ ចាសអញ្ចឹងការសម្ភាសហ្នឹងវាមានតែប៉ុណ្ណឹងទេ ហើយនាងខ្ញុំសូមថ្លែងអំណរគុណដល់ពូខ្លាំងមែនទែន ហើយខ្ញុំដឹងថាកូនចៅរបស់ពូជំនាន់ក្រោហ្នឹងពួកគាត់នឹងបានស្ដាប់នៅការសម្ភាសរបស់ពូហើយនឹងអំពីជីវិតស្អីៗខ្លះអញ្ចឹងហ្នឹងណាបង ចាសខ្ញុំសូមអរគុណដល់ពូច្រើនហើយណាបងសម្រាប់ថ្ងៃហ្នឹងណាពូ ចាសហ្នឹងហើយអញ្ចឹងនាងខ្ញុំសូមអរគុណខ្លាំងមែនទែនពូសម្រាប់ថ្ងៃនេះដែលពូបានឱ្យនាងខ្ញុំបានធ្វើការសម្ភាសដែលសម្រាប់ដាក់នៅក្នុងវេបសាយខាងលើដែលខ្ញុំបាននិយាយប្រាប់រួចហើយ អញ្ចឹងពួកខ្ញុំអរគុណពូខ្លាំងមែនទែនហើយអ្វីៗទាំងអស់នេះ អញ្ចឹងកូនចៅរបស់ពូនឹងបានឮហើយបើសិនជាកូនចៅរបស់ពូ ពួកគាត់ចង់ឮពួកគាត់នឹងចូលទៅកាន់វេបសាយមួយនេះដែលមាននៅក្នុងអាស័យដ្ឋានមួយហ្នឹងបានដូចជាការដែលខ្ញុំបានរៀបរាប់នៅខាងលើអញ្ចឹង រួចហើយពួកគាត់នឹងបានឮពីជីវប្រវត្តិទាំងឡាយរបស់ពូ ហើយអញ្ចឹងសម្រាប់ថ្ងៃហ្នឹងខ្ញុំសូមអរគុណពូ។

ខ៖ បាទហ្នឹងហើយ។

ខ៖ ចាស៕